**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ០២៤៣ ព.ណ.កសម

ថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០២៥

**ជម្រាបមក**

**លោក/លោកស្រី ប្រធានក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ឯ.ក**

**កម្មវត្ថុ៖** ករណីស្នើសុំការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្ត ពាក់ម៉ាក “**FORD**” និង “ ”។

**យោង** ៖-ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-ប្រកាសលេខ ០១១៧ ព.ណ កសប ប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក

-លិខិតស្នើសុំរបស់ **ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ឯ.ក** ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៤

-លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន FORD MOTOR COMPANY ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៤។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបថា យោងតាមច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ មាត្រា៣ និងមាត្រា១១ និង យោងតាមប្រកាស ស្តីពី នីតិវិធីបញ្ជាក់ និងការកត់ត្រាលិខិតប្រគល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក ដែល ប្រការ៨ ចែងថា ដើម្បីទទួលបានសិទ្ធិផ្តាច់មុខលើម៉ាក អ្នកស្នើសុំត្រូវចុះបញ្ជីម៉ាក នៅក្រសួងពាណិជ្ជកម្ម។

ក្នុងករណីដែលក្រុមហ៊ុនបានចុះបញ្ជីម៉ាក “**FORD**” និង “ ” អាចធ្វើការស្នើសុំកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខចំពោះតែម៉ាក “**FORD**” និង “ ” ប៉ុណ្ណោះ។ ចំពោះប្រភេទរថយន្តដែលមានម៉ាកនៃម៉ូដែលជាប់ដោយឡែកជ្រកក្រោមម៉ាក “**FORD**” និង “ ” ដូចជា ម៉ាក TERRITORY, EVEREST, EXPLORER, BRONCO, RANGER, ECOSPORT, TRANSIT, MUSTANG។ល។ ត្រូវធ្វើការចុះបញ្ជីម៉ាកនៃម៉ូដែលនោះ ជាមុនសិន ក្នុងករណីដែលត្រូវស្នើសុំកត់ត្រាសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ចំពោះម៉ាកនៃម៉ូដែលនីមួយៗ នៅក្រសួងពាណិជ្ជកម្ម។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុនជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាព។

សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ទទួលនូវការរាប់អានពីខ្ញុំ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**អ៊ុក-ប្រជា**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ០២៤ /ព.ណ.ភ.ណ.រ

ថ្ងៃសុក្រ ១១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០២៥

**ជម្រាបមក**
**លោក/លោកស្រីប្រធានក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក**

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្ត គ្រឿងបន្លាស់ និងគ្រឿងតុបតែងម៉ាក **"FORD"** និង Ford ដែលមានភ្ជាប់ម៉ូដែលមកជាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា) ម.ក**។

**យោង:**- មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា) ម.ក** ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០២៤
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Ford Motor Company ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០២៤
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣៣០៦៩/០៩ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៣៣០៧០/០៩ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើរថយន្ត គ្រឿងបន្លាស់ និងគ្រឿងតុបតែងពាក់ម៉ាកខាងលើ របស់ក្រុមហ៊ុន **អ អិម អេ (ខេមបូឌា) ម.ក** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Ford Motor Company ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រា និងតម្កល់សិទ្ធិផ្តាច់មុខនេះ មានសុពលភាពរយៈពេល ០២(ពីរ)ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Ford Motor Company ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតផ្តាច់មុខនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា ហើយត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក-ប្រុជា**

*<u>ចម្លងជូន:</u>*
*- ទីស្តីការគណៈរដ្ឋមន្ត្រី*
*- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី*
*- ខុទ្ទកាល័យ ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី*
*- ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*
*- ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*- អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
*- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
*- អគ្គនាយកដ្ឋានពន្ធដារ*
*- ឯកសារ-កាលប្បវត្តិ*

# បញ្ជី

## ម៉ូឌែលភ្ជាប់ និងលិខិតកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ

## ម៉ាក "Ford" និង

| ល.រ | ឈ្មោះ ម៉ូដែល |
|---|---|
| 1 | Ecosport |
| 2 | Mustang |
| 3 | Bronco |
| 4 | Everest Sport |
| 5 | Everest XLT |
| 6 | Everest Titanium |
| 7 | Ranger Single Cab |
| 8 | Ranger XL |
| 9 | Ranger XLT |
| 10 | Ranger XLS |
| 11 | Ranger Wildtrak |
| 12 | Ranger Raptor |
| 13 | F150 Raptor |
| 14 | Expedition Platinum |
| 15 | Explorer Limited |
| 16 | Territory |
| 17 | Transit Bus |
| 18 | Everest Wildtrak |
| 19 | Stormtrak |